# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៤ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ

~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ហៅកាត់ថា " អ.ប.អ.ព " ដែលស្ថិតនៅក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី។
~~~~~~~~

**មាត្រា២ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ឱម យ៉ិនទៀង** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **មល់ រឿប** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម **ញ៉ែម សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-ឯកឧត្តម **ឆ័យ ឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | អនុប្រធាន |
| ៥-ឯកឧត្តម **ឆេង សារឿន** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច | សមាជិក |
| ៦-ឯកឧត្តម **ហង់ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **នេត សាវឿន** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-ឯកឧត្តមឧត្តមសេនីយ៍ឯក **ជុំ ហាក់** | មេបញ្ជាការរងកងទ័ពជើងគោក | សមាជិក |
| ៩-ឯកឧត្តម **ប៊ុន ហុន** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០-ឯកឧត្តមឧត្តមសេនីយ៍ទោ **ខខ្យ ពិសេន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១១-លោក **សរ សម្បត្តិ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកប្រចាំការ |

**មាត្រា៣ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានបេសកកម្មក្នុងការធ្វើសកម្មភាព ដោយផ្តោតសំខាន់លើកត្តាជាសារវ័ន្តពា ដែលមានភាពប្រទាក់ក្រឡាគ្នា គឺ ការបង្ការទប់ស្កាត់ជាមុន ការពង្រឹងការអនុវត្តច្បាប់ និងការគាំទ្រពីមហាជន ក្នុងការប្រយុទ្ធប្រឆាំងកំចាត់អំពើពុករលួយ ។

អង្គភាពប្រឆាំងអំពើពុករលួយមានតួនាទី និងភារកិច្ច ដូចតទៅ :

-ប្រមែប្រមូលគ្រប់ឯកសារ និងព័ត៌មានពាក់ព័ន្ធអំពើពុករលួយគ្រប់ប្រភេទ និងរក្សាការសម្ងាត់នៃប្រភពទទួលព័ត៌មាន ស្តីពីការកើតមានអំពើពុករលួយ

-ពិនិត្យ និងរៀបចំឯកសារ ព្រមទាំងលើកឡើងគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការប្រឆាំងកំចាត់អំពើពុករលួយ ដែលមានចរិតជាចក្ខុវិស័យ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

-រៀបចំកសាងផែនការសកម្មភាពប្រឆាំងអំពើពុករលួយ

-ទទួល និងពិនិត្យរាល់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយ

-តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងធ្វើការសិក្សាស្រាវជ្រាវ ព្រមទាំងលើកឡើងនូវវិធានការនានាពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ក្រុមហ៊ុនរដ្ឋ និងអាជ្ញាធរដែនដីខេត្ត ក្រុង ព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន

-អនុវត្តនូវវិធានការរបស់រាជរដ្ឋាភិបាល តាមរយៈការអប់រំ ឃោសនា ផ្សព្វផ្សាយ ការបង្ការ ការទប់ស្កាត់ ការជំរុញការអនុវត្តច្បាប់ និងការបង្ក្រាបអំពើពុករលួយ

-ធ្វើទំនាក់ទំនង សម្របសម្រួល និងកៀរគរធនធាន និងជំនួយអន្តរជាតិ

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានរចនាសម្ព័ន្ធដូចតទៅ :

១-ផ្នែករដ្ឋបាល ហិរញ្ញកិច្ច និងធនធានមនុស្ស

២-ផ្នែកអប់រំ បង្ការ ទប់ស្កាត់ និងសហប្រតិបត្តិការ

៣-ផ្នែកស៊ើបអង្កេត

៤-ផ្នែកជំរុញការអនុវត្តច្បាប់ ។

ផ្នែកនីមួយៗត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា៥ .-**

ផ្នែករដ្ឋបាល ហិរញ្ញកិច្ច និងធនធានមនុស្ស មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួល និងពិនិត្យរាល់លិខិតចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងពាក្យបណ្តឹងនានា ព្រមទាំងបញ្ជូនលិខិតឯកសារទៅផ្នែកថ្នាក់ដឹកនាំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ

-លើក និងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងគ្រប់គ្រងគណនេយ្យ និងហិរញ្ញកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-គ្រប់គ្រង និងរៀបចំបណ្តុះបណ្តាលធនធានមនុស្ស ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកំពស់សមត្ថភាពជំនាញដល់មន្ត្រីរាជការក្នុងអង្គភាព និងក្រសួង ស្ថាប័នពាក់ព័ន្ធ

-ធ្វើសេចក្តីព្រាងបូកសរុបរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់អង្គភាព តាមកាលកំណត់ ជូនប្រធានអង្គភាព ពិនិត្យ និងសម្រេច

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៦ .-**

ផ្នែកអប់រំ បង្ការ ទប់ស្កាត់ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ចដូចតទៅ :

-កសាងផែនការសកម្មភាព ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើពុករលួយតាមទស្សនៈ កម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍ជាតិ

-កសាងឯកសារយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយក្នុងអភិបាលកិច្ចល្អ

-ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ អន្តរជាតិ និងបង្កើតកម្មវិធីផ្សេងៗ ដើម្បីផ្សព្វផ្សាយដល់មហាជនឱ្យយល់ដឹងអំពីផលវិបាកនៃអំពើពុករលួយ

-ធ្វើការអប់រំក្រមសីលធម៌វិជ្ជាជីវៈដល់មន្ត្រីរាជការ អាជ្ញាធរដែនដី សិស្សានុសិស្ស និស្សិត កងកម្លាំងប្រដាប់អាវុធ និងមហាជន ដើម្បីចូលរួមក្នុងការបង្ការទប់ស្កាត់ និងកំចាត់អំពើពុករលួយ

-ជំរុញ និងលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ ឱ្យចូលរួមផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ

-ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងស្វែងរកជំនួយឧបត្ថម្ភពីដៃគូនានា ទាំងសម្ភារៈ បច្ចេកទេសជំនាញ និងថវិកា

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៧ .-**

ផ្នែកស៊ើបអង្កេត មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួលពាក្យបណ្តឹង និងស្វែងរកព័ត៌មាន ដែលពាក់ព័ន្ធនឹងអំពើពុករលួយ

-សិក្សាស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធនឹងអំពើពុករលួយ រួចធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអង្គភាព

-សហការជាមួយសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីធ្វើការស៊ើបអង្កេតដល់ទីកន្លែងនូវរាល់ករណីពាក់ព័ន្ធនឹងការក្លែងបន្លំ ការកិបកេងទ្រព្យសម្បត្តិរដ្ឋ ការបាត់បង់ថវិកាជាតិ និងសកម្មភាពនៃអំពើពុករលួយផ្សេងទៀត

-តាមដានលើឯកសារ និងសកម្មភាពនៃការងារចំណូល ចំណាយថវិកាជាតិ និងការប្រើប្រាស់ជំនួយជាតិ និងអន្តរជាតិ នៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អាជ្ញាធរដែនដីខេត្ត ក្រុង គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងក្រុមហ៊ុនរដ្ឋ ដើម្បីធ្វើការវាយតម្លៃ សន្និដ្ឋាន និងលើកវិធានការជូនថ្នាក់ដឹកនាំអង្គភាព

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៨ .-**

ផ្នែកជំរុញការអនុវត្តច្បាប់ មានតួនាទី និងភារកិច្ចដូចតទៅ :

-សិក្សា និងវិភាគពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើពុករលួយ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់បទល្មើស រួចស្នើសុំការសម្រេចពីថ្នាក់ដឹកនាំអង្គភាព

-សហការជាមួយផ្នែកស៊ើបអង្កេត និងផ្នែកពាក់ព័ន្ធ ព្រមទាំងនគរបាលយុត្តិធម៌ ក្នុងការរៀបចំបែបបទបញ្ជូនសំណុំរឿង និងជនល្មើសទៅតុលាការតាមនីតិវិធីជាធរមាន

-សិក្សាស្រាវជ្រាវឯកសារច្បាប់ និងលិខិតបទដ្ឋាននានា ទាំងក្នុង និងក្រៅប្រទេសដែលពាក់ព័ន្ធនឹងការប្រឆាំងនឹងអំពើពុករលួយ

-តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួង ស្ថាប័ន ដើម្បីធានាបាននូវភាពសុចរិត ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៩ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានខ្ទង់ថវិកាដោយឡែកមួយ នៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ធនធាន និងថវិការបស់អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវផ្គត់ផ្គង់ដោយ :

-ថវិកាជាតិ

-ហិរញ្ញប្បទានពីអង្គការជាតិ និងអន្តរជាតិ ។

**មាត្រា១០ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា១១ .-**

អនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អភិបាលខេត្ត ក្រុង និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ